**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**


# សេចក្តីជូនដំណឹង

## ស្តីពី

## ការរង់ចាំជួបដោះស្រាយជាមួយតំណាង ឬបងប្អូនអតីតបុគ្គលិក នៅក្រុមហ៊ុន ណាហ្គាវើលដ៍ លីមីធីត អំពីការពិនិត្យផ្ទៀងផ្ទាត់ឡើងវិញនូវ ការទូទាត់ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនតំណាង ឬបងប្អូនអតីតបុគ្គលិកដែលកំពុងធ្វើការតវ៉ា និយោជក និងសាធារណជន ឱ្យបានជ្រាបថា ដើម្បីបន្តការពារឱ្យបាននូវផលប្រយោជន៍ស្របច្បាប់របស់បងប្អូនអតីតបុគ្គលិកក្រុមហ៊ុន ណាហ្គាវើលដ៍ លីមីធីត ដែលកំពុងធ្វើការតវ៉ា ក្រសួងបានត្រៀមទទួលជួបជាមួយតំណាង ឬបងប្អូនអតីតបុគ្គលិក ដើម្បីពិនិត្យផ្ទៀងផ្ទាត់ឡើងវិញនូវការទូទាត់ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងាររបស់ក្រុមហ៊ុនជូនដល់បងប្អូនអតីតបុគ្គលិក នៅទីស្តីការក្រសួង។

ជាថ្មីម្តងទៀត ក្នុងគោលបំណងឈានទៅបញ្ចប់ករណីវិវាទនេះ ក្រសួងសូមអំពាវនាវដល់តំណាង ឬបងប្អូនអតីតបុគ្គលិកក្រុមហ៊ុន ណាហ្គាវើលដ៍ លីមីធីត ដែលកំពុងធ្វើការតវ៉ាដោយលើកមូលហេតុថា និយោជកបានទូទាត់ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារដល់ខ្លួនមិនត្រឹមត្រូវតាមច្បាប់ សូមអញ្ជើញមកក្រសួងនៅរៀងរាល់ម៉ោងធ្វើការ ឬតាមរយៈទូរស័ព្ទលេខ ០១២ ៨៧២ ១៦១/០៩២ ៨៨៨ ៥៨៥/០៨៧ ៥២៥ ៦៥៦ ដោយផ្តល់នូវព័ត៌មានអំពីប្រាក់ឈ្នួល, ប្រាក់អត្ថប្រយោជន៍ដែលខ្លួនធ្លាប់ទទួលបាន, រូបមន្តគណនា និងមូលដ្ឋានគណនាដែលខ្លួនចង់បាន ដើម្បីក្រសួងធ្វើការផ្ទៀងផ្ទាត់ឡើងវិញ។ ក្រសួងនឹងបង្គាប់ឱ្យនិយោជកធ្វើការទូទាត់សំណងបន្ថែមដល់បងប្អូន ក្នុងករណីដែលក្រសួងទទួលបានព័ត៌មានពេញលេញ ហើយរកឃើញថា មានភាពលម្អៀងក្នុងការគណនាពិតប្រាកដមែន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម អតីតបុគ្គលិកដែលកំពុងធ្វើការតវ៉ា និយោជក និងសាធារណជន ជ្រាបជាព័ត៌មាន។

*ថ្ងៃចន្ទ ១កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥*

*រាជធានីភ្នំពេញ ថ្ងៃទី៣ ខែមករា ឆ្នាំ២០២២*